២កូរិនថូស១២:១-១២

# ជំពូក ១២

***ឆាទចនា** សេចក្តីបង្ហាញអោយឃើញលោកប៉ុល*

*ពិតជាសាវ័ករបស់ព្រះជាម្ចាស់មែន*

នៅក្នុងសម័យឆ្នាំ១៩៦០ និង១៩៧០ គេមានការរំភើបយ៉ាងខ្លាំងដោយសារមនុស្សលោកបានជិះយានអវកាសឡើងទៅដល់ឋានព្រះចន្ទជាលើកដំបូងបង្អស់។ លុះគេត្រឡប់មកវិញ គេបានប្រកាសថា គេទទួលបានជោគជ័យសំខាន់ជាទីបំផុត ដ្បិតមនុស្សលោកអាចធ្វើដំណើរទៅទីនោះ តាំងពីមនុស្សយើងមានកំណើតលើផែនដីនេះ។ បើតាមសេចក្តីសន្និដ្ឋាន មនុស្សលោកអាចសម្រេចការធ្វើដំណើរដ៏ឆ្ងាយទៅដល់ឋានព្រះចន្ទ ជាជោគជ័យយ៉ាងធំមែន។ ប៉ុន្តែ បើយើងប្រៀបធៀបចម្ងាយចន្លោះផែនដីនិងព្រះអាទិត្យ ផ្កាយព្រះអង្គារ ព្រមទាំងឋានដទៃទៀតដែលមាននៅលើចក្រវាលយើងនេះ មនុស្សលោកមិនទាន់បានសម្រេចអ្វីជាដុំកំភួននៅឡើយទេ។

នៅក្នុងព្រះគម្ពីរ មានសម្តែងពីមនុស្សបីនាក់ ដែលបានធ្វើដំណើរទៅដល់ឋានលើ រួចហើយត្រឡប់មកផែនដីវិញ។ លោកទាំងបីរូបនោះមិនមែនជាតួអង្គនៅក្នុងគម្ពីរសញ្ញាចាស់ទេ។

ចុះលោកហេណុក និងលោកអេលីយ៉ា តើលោកមិនបានធ្វើដំណើរទៅដល់ស្ថានសួគ៌ទេឬ? ខ្ញុំយល់ថា គាត់មិនទាន់បានទៅដល់ស្ថានសួគ៌ទេ ពីព្រោះព្រះអម្ចាស់យេស៊ូវមានបន្ទូលនៅគម្ពីរយ៉ូហាន៣:១៣ថា “គ្មានអ្នកណាបានឡើងទៅស្ថានសួគ៌ឡើយ មានតែព្រះអង្គដែលយាងចុះពីស្ថានសួគ៌មកប៉ុណ្ណោះ គឺជាកូនមនុស្សដែលនៅស្ថានសួគ៌នោះឯង”។ ព្រះគម្ពីរសម្តែងថា ស្ថានសួគ៌មានបីជាន់។ ជាន់ទីមួយ គឺជាលំហអាកាសដែលសត្វស្លាបអាចហើរបាន។ ជាន់ទីពីរ គឺជាស្ថានសួគ៌ដែលមានផ្កាយរះព្រោងព្រាត។ យើងហៅថាលើមេឃ។ ឯស្ថានសួគ៌ជាន់ទីបី គឺជាកន្លែងដែលព្រះជាម្ចាស់តាំងបល្ល័ង្ករបស់ព្រះអង្គធ្វើជាដំណាក់របស់ទ្រង់។ ហោរាអេលីយ៉ា និងលោកហេណុកបានឡើងទៅស្ថានសួគ៌ ជាដំណាក់ព្រះទេ គឺបានឡើងទៅដល់លោក ត្រឹមជាន់ទីមួយ ឬជាន់ទីពីរ។ មកទល់នៅពេលនេះ មិនទាន់មានមនុស្សណាម្នាក់បានឡើងទៅដល់ស្ថានសួគ៌ ជាដំណាក់របស់ព្រះជាម្ចាស់នៅឡើយ។ ព្រះអម្ចាស់យេស៊ូវមានបន្ទូលថា ទ្រង់ជាកូនមនុស្សដែលយាងចុះពីស្ថានសួគ៌។ ព្រះអង្គជាបុគ្គលទីមួយ រស់នៅស្ថានសួគ៌ដែលយាងមកលើផែនដីនេះ។ មានបុគ្គលពីរនាក់ទៀតបានទៅដល់ស្ថានសួគ៌ជាន់ទីបីជាដំណាក់ព្រះគង់នៅដែរ។ ពេលដែលលោកត្រូវជាប់មន្ទីរឃុំឃាំងនៅកោះដាស់ម៉ុស ព្រះវិញ្ញាណនៃព្រះបានលើកលោកយ៉ូនហានយកទៅដល់ស្ថានសួគ៌។ លោកបានកត់ត្រាទុកសេចក្តី ដែលលោកបានឃើញ និងបានឮនៅក្នុងព្រះគម្ពីរវិវរណៈ។ លោកបានឡើងទៅដល់ស្ថានសួគ៌ជាន់ទីបី ជាកន្លែងដែលបល្ល័ង្ករបស់ព្រះជាម្ចាស់តាំងនៅ។ លោកយ៉ូហានសរសេរបញ្ជាក់ថា “ក្រោយនោះមក ខ្ញុំក្រឡេកទៅឃើញមានទ្វារ១ចំហ

នៅស្ថានសួគ៌ ហើយសំឡេងដែលខ្ញុំបានឮ ដូចជាសូរត្រែជាមុនដំបូងនោះ ក៏មានបន្ទូលមកខ្ញុំថា ចូរឡើងមកឯណេះ អញនឹងបង្ហាញឱ្យឯងឃើញការ ដែលត្រូវមកខាងក្រោយទៀត ស្រាប់តែខ្ញុំបានត្រឡប់ជានៅដោយវិញ្ញាណ ហើយឃើញមានបល្ល័ង្ក១ ដាក់នៅលើស្ថានសួគ៌ ក៏មាន១អង្គគង់នៅលើបល្ល័ង្កនោះ” (វិវរណៈ៤:១-២)។ លោកយ៉ូហានជាបុគ្គលទីមួយ។ ឯបុគ្គលទីពីរ គឺសាវ័កប៉ុល។ លោកបានឡើងទៅដល់ស្ថានសួគ៌ទីបីដែរ។ លោកបានកត់ត្រារឿងនោះនៅក្នុងជំពូកដែលយើងសិក្សាថ្ងៃនេះ។

ដូច្នេះមានតួអង្គបីរូប ដែលបានឡើងទៅដល់ស្ថានសួគ៌ជាន់ទីបី។ បុគ្គលទាំងបីរូបនោះគឺ ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដែលទ្រង់ជាព្រះបើកសម្តែងជារូបភាពសាច់របស់មនុស្សលោក។ ទ្រង់ស្គាល់ស្ថានសួគ៌ជាងគេ តែព្រះអង្គមានបន្ទូលតិចបំផុតពីស្ថាននេះ។ លោកយ៉ូហានបានឃើញស្ថានសួគ៌ដែរ តែលោកសរសេរតិចតួចដូចមានរៀបរាប់ក្នុងគម្ពីរវិវរណៈស្រាប់។ ឯសាវ័កប៉ុលក៏មិនមាននិយាយអ្វីច្រើនពីស្ថានសួគ៌ដែរ។

សាវ័កប៉ុលមានប្រសាសន៍ថា លោកមិនចង់និយាយពីស្ថានសួគ៌ លើកលែងតែគេបង្ខំអោយលោកបំភ្លឺថា លោកពិតជាសាវ័ករបស់ព្រះអម្ចាស់ ទើបលោកមានប្រសាសន៍ ពីដំណើរដែលលោកបានធ្វើដំណើរទៅដល់ស្ថានសួគ៌ជាន់ទីបី។

## បទពិសោធន៍របស់សាវ័កប៉ុល

**ប្រាកដជាគ្មានប្រយោជន៍ឱ្យខ្ញុំអួតខ្លួនទេ ប៉ុន្តែ ខ្ញុំនឹងនិយាយពីការជាក់ស្តែង នឹងការបើកសំដែងមកពីព្រះអម្ចាស់ទៀត (២កូរិនថូស ១២:១)។**

សាវ័កប៉ុលបានសរសេរពីហេតុការណ៍ជាច្រើន បញ្ជាក់ថាលោកពិតជាបានរងទុក្ខដោយសារព្រះនាមព្រះអម្ចាស់យេស៊ូវ។ ក្នុងការបម្រើព្រះជាម្ចាស់ លោកមិនសូវទទួលបានការសរសើរពីមនុស្សលោកប៉ុន្មានទេ។ ខ្ញុំយល់ថា ព្រះវិញ្ញាណបរិសុទ្ធនៃព្រះបណ្តាលអោយលោកសរសេរបទពិសោធន៍ទាំងនោះ ដើម្បីកុំអោយមានមនុស្សណាម្នាក់អួតថា គេរងទុក្ខខ្លាំងជាងសាវ័កប៉ុលទៅទៀត"។

បើយើងប្រៀបធៀបបទពិសោធន៍របស់សាវ័កប៉ុល ទៅនឹងបទពិសោធន៍របស់យើង ចម្រៀងដែលច្រៀងទាំងអម្បាណមាណ ដូចជាបទដែលចម្រៀងថា "គ្រប់ទាំងអស់ខ្ញុំថ្វាយ ព្រះយេស៊ូវអើយ ទាំងអស់ខ្ញុំថ្វាយដាច់ដល់ទ្រង់"។ មានន័យតិចតួចណាស់ ពីព្រោះយើងច្រៀងថាគ្រប់ទាំងអស់ខ្ញុំថ្វាយមែន ប៉ុន្តែ ដល់ពេលដាក់តង្វាយ គេបើកាបូបយកលុយសន្លឹកណាដែលតូចជាងគេបំផុត ហើយខ្លះយកលុយដែលចាយមិនកើតដាក់ក្នុងថង់តង្វាយទៀតផង។ បើមាត់ច្រៀងផ្សេង ចិត្តធ្វើផ្សេង កិរិយានោះរាប់ថាគ្មានប្រយោជន៍អ្វីឡើយ។

សព្វថ្ងៃនេះ យើងចូលចិត្តច្រៀងបទសរសើរព្រះ តែទង្វើរបស់យើង មិនបានប្រព្រឹត្តកិរិយាណាអោយសមស្របនឹងបទចម្រៀងដែលយើងបានច្រៀង។ បើដូច្នោះ

មែន ចម្រៀងបែបនោះ ពិតជាមានបង្កប់គំនិតមានពុតរបស់យើងជាយថាហេតុ។ បើយើងច្រៀងចម្រៀងសរសើរ យើងគួរច្រៀងដូចបទលោកអ៊ីសាក់-វ៉ាត់ បាននិពន្ធដូចខាងក្រោមនេះថា:

> ចូរមើលព្រះអង្គសង្គ្រោះនៃខ្ញុំបង្ហូរព្រះលោហិត ទ្រង់បង់ជីវិតដ៏ថ្លៃឧត្តម
> ទ្រង់ញែកអង្គទ្រង់សម្រាប់រូបខ្ញុំ តើខ្ញុំជាអ្វី បើខ្ញុំមិនមែនជាដូចដង្កូវទេ?

នៅក្នុងបទចម្រៀងដែលយើងច្រៀង យើងត្រូវលើកតម្កើងព្រះអម្ចាស់យេស៊ូវ ទាំងបបូរមាត់ ទាំងកិរិយាប្រព្រឹត្តរបស់យើងផង ទើបចម្រៀងនោះមានខ្លឹមសារសម្រាប់យើង។

ម្យ៉ាងវិញទៀត សព្វថ្ងៃយើងតែងតែឮទីបន្ទាល់របស់បុរសស្ត្រី ស្តីពីដំណើរប្រែចិត្តជឿព្រះអម្ចាស់យេស៊ូវ។ ទីបន្ទាល់គ្រប់ម៉ាត់ទាំងអស់ សុទ្ធតែមានលក្ខណៈហាក់ដូចជាខ្លាំងក្លាណាស់។ យើងមិនសូវឮគេនិយាយពីទីបន្ទាល់ធម្មតាទេ។ ជួនកាលអ្នកខ្លះនិយាយអំពីជីវិតចាស់មុនជឿព្រះអង្គថា គេកាចសាហាវយង់ឃ្នង ធ្វើការអាក្រក់គ្រប់បែបយ៉ាង។ ស្រាប់តែក្រោយពីជឿព្រះអង្គ គេប្តូរផ្លាស់ចិត្តមកធ្វើការល្អតាមព្រះយេស៊ូវវិញ។ ទីបន្ទោល់នោះមើលទៅហាក់ដូចជា គេលើកខ្លួនឯងជាងលើកព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ បើទីបន្ទាល់ណា មិននិយាយលើកព្រះអម្ចាស់យេស៊ូវគ្រីស្ទ ព្រមទាំងថ្វាយសិរីល្អដល់ទ្រង់ទេ ទីបន្ទាល់នោះគ្រាន់តែយកព្រះយេស៊ូវគ្រីស្ទមកលាបៗតែប៉ុណ្ណោះ។

ខ្ញុំបានឮបុរសម្នាក់និយាយថា គាត់ខំកាន់សាសនាមួយ។ បន្ទាប់ពីយល់ព្រះបន្ទូលព្រះយេស៊ូវ គាត់យល់ឃើញថា ព្រះអម្ចាស់យេស៊ូវអាចជួយបំពេញអោយគាត់រីតតែមានលទ្ធភាពអាចធ្វើតាមសាសនាដែលកំពុងតែកាន់នោះបាន។ ចាប់ពីពេលនោះមក គាត់យាងព្រះអម្ចាស់យេស៊ូវអោយគង់នៅក្នុងចិត្តគាត់។ ទ្រង់ជាព្រះតែមួយអង្គគត់នៅក្នុងចិត្តគាត់។ ទីបន្ទាល់សាមញ្ញបែបនេះ មើលទៅហាក់ដូចជាពិតច្រើនជាង។ ទីបន្ទាល់ដែលពិត មិននិយាយលើកខ្លួនឯង គឺលើកតម្កើងព្រះយេស៊ូវ។

បន្ទាប់ពីរៀបរាប់រឿងទុក្ខលំបាករបស់លោក ដែលលោកបានឆ្លងកាត់ក្នុងនាមព្រះអម្ចាស់យេស៊ូវ សាវ័កប៉ុលមានប្រសាសន៍ពីនិម្មិតដែលលោកបានទទួលពីព្រះអម្ចាស់មក។ យើងដឹងរួចហើយថា ព្រះអម្ចាស់បានបើកសម្តែងដល់សាវ័កប៉ុលអោយឃើញទ្រង់ ពេលលោកប៉ុលធ្វើដំណើរតាមផ្លូវឆ្ពោះទៅទីក្រុងដាម៉ាស។ ប៉ុន្តែ សាវ័កប៉ុលនិយាយតិចណាស់ពីដំណើរនោះ។ ឥឡូវលោកបរិយាយពីហេតុការណ៍នោះម្តងទៀតហើយ។

**ខ្ញុំស្គាល់មនុស្សម្នាក់នៅក្នុងព្រះគ្រីស្ទ ដែលបានលើកឡើងទៅស្ថានសួគ៌ នៅជាន់ទី៣ នោះប្រហែល១៤ឆ្នាំមកហើយ នោះបើក្នុងរូបកាយ ឬក្រៅពីរូបកាយ នោះខ្ញុំមិនដឹងទេ មានតែព្រះដែលទ្រង់ជ្រាប (២កូរិនថូស១២:២)។**

ព្រះយេស៊ូវមានបន្ទូលពីសត្វហើរលើអាកាស ពោលគឺជាឋានដែលសត្វអាចហើរបាន។ សត្វស្លាបមិនអាចហើរហួសពីឋានរបស់ខ្លួនដែលអាចហើរបានទេ។ ទីដែលខ្ពស់ជាងឋានសត្វស្លាបអាចហើរបាន គឺជាឋានដែលហ្វូងផ្កាយទាំងពួងតាំងនៅ។ ឋាននោះមិនមែនជាដំណាក់ព្រះជាម្ចាស់ទេ។ ដំណាក់ព្រះអង្គ គឺស្ថិតនៅក្នុងស្ថានសួគ៌ជាន់ទីបី។ កាលពួកអវកាសបានឡើងទៅដល់ឋានព្រះចន្ទ ទាំងពួកអវកាសសាសន៍អាមេរិកកាំង និងពួកអវកាសសាសន៍រុស្ស៊ី គេនិយាយថា គេមិនឃើញព្រះគង់នៅទីនោះទេ។ ពាក្យសម្ដីទាំងនោះរាប់ថា "អ្នកប្រាជ្ញចុះរណ្ដៅ" មែន។ ពួកអ្នកប្រាជ្ញទាំងនោះមិនអាចឃើញព្រះ ពីព្រោះគេមិនអាចឡើងទៅដល់ឋានទីបី ដែលជាបល្ល័ង្ករបស់ព្រះជាម្ចាស់គង់នៅទីនោះ។

សាវ័កប៉ុលបរិយាយពីបទពិសោធន៍របស់លោក ដែលព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គលើកលោកទៅឋានទីបី។ លោកបានកំណត់ថ្ងៃអោយយើងដឹងនៅក្នុងព្រះគម្ពីរ។ ហេតុការណ៍នោះកើតឡើងប្រមាណដប់បួនឆ្នាំ មុនលោកសរសេរសំបុត្រទៅកាន់ពួកជំនុំក្រុងកូរិនថូសជាលើកទីពីរ។ ពេលនោះ ប្រមាណជាពេលដែលលោកធ្វើដំណើរបេសកកម្មលើកទីមួយ។ នៅពេលលោកធ្វើដំណើរបេសកកម្មលើកទីមួយលោកត្រូវគេធ្វើទុក្ខបុកម្នេញ រហូតដល់សន្លប់បាត់បង់ជីវិតនៅទីក្រុងលីស្ត្រា។ ដំណើរនោះមានចែងក្នុងគម្ពីរកិច្ចការ១៤:១៩-២០ថា "មានពួកសាសន៍យូដាខ្លះ មកពីអាន់ទីយ៉ូក នឹងអ៊ីកូនាម គេបញ្ចុះបញ្ចូលហ្វូងមនុស្ស ឱ្យចោលប៉ុលនឹងថ្ម រួចគេអូសគាត់ចេញទៅក្រៅទុកចោល ដោយស្មានថាបានស្លាប់ហើយ ប៉ុន្តែ ពួកសិស្សមកចោមព័ទ្ធ

គាត់ រួចគាត់ក្រោកឡើងចូលទៅក្នុងទីក្រុងវិញ ហើយដល់ថ្ងៃស្អែក គាត់នឹងបាណាបាស ក៏ចេញទៅឯឌើបេ"។

តើសាវ៉កប៉ុលស្លាប់ឬទេក្នុងពេលនោះ? ខ្ញុំយល់ថា បើអ្នកប៉ងសម្លាប់សាវ៉ក ប៉ុលមិនយល់ថា សាវ៉កប៉ុលស្លាប់ទេ គេមិនទុកលោកនៅទីនោះអោយនៅតែឯង ឡើយ។ ខ្ញុំយល់ថាសាវ៉កប៉ុលពិតជាស្លាប់ តែព្រះអម្ចាស់បានប្រោសលោកអោយរស់ ឡើងវិញ។ សាវ៉កប៉ុលសម្តែងថា លោកមិនប្រាកដក្នុងចិត្តថា តើរឿងនោះគ្រាន់តែ ជានិម្មិត ឬមួយក៏លោកទៅដល់ឋានជាន់ទីបីដូចលោកបានឃើញមែន។ លោកគ្រាន់តែ បរិយាយពីបទពិសោធន៍របស់លោកយ៉ាងខ្លីតែប៉ុណ្ណោះទេ។

**ខ្ញុំស្គាល់មនុស្សនោះ (ទោះបើក្នុងរូបកាយ ឬក្រៅពីរូបកាយក្តី ខ្ញុំមិនដឹងទេ មានតែព្រះដែលទ្រង់ជ្រាប)ថា (២កូរិនថូស១២:៣)។**

យើងអាចសួរម្តងទៀតថា តើសាវ៉កប៉ុលស្លាប់មែនឬទេ? តើព្រលឹងរបស់ លោកធ្វើដំណើរទៅដល់ឋានទីបីឬទេ? សាវ៉កប៉ុលមិនប្រាកដក្នុងចិត្តដែរ។ យើងក៏មិន ត្រូវនិយាយអ្វីអោយប្រាកដជាងសាវ៉កប៉ុលក៏ទេដែរ។ ខ្ញុំយល់ថា សាវ៉កប៉ុលពិតជាស្លាប់ មែន ហើយព្រះជាម្ចាស់បានប្រោសលោកអោយរស់ឡើងវិញ។ ឯលទ្ធផលនៃហេតុ ការណ៍នេះ លោកសន្លប់ធំ ឬលោកស្លាប់ដួតតែគ្នាទេ គឺលោកបានឃើញស្ថានសួគ៌ជាន់ ទីបី។ លោកពណ៌នាដូចខាងក្រោមនេះ

> **អ្នកនោះបានលើកឡើងដល់ស្ថានបរមសុខ ហើយបានឮពាក្យដែលថ្លែងប្រាប់មិនបាន ក៏គ្មានច្បាប់ឱ្យមនុស្សណានិយាយឡើយ (២កូរិនថូស១២:៤)។**

មនុស្សច្រើនណាស់ព្យាយាមសរសេរអត្ថបទ សរសេរសៀវភៅជាច្រើនច្បាប់ ច្រើនក្បាល ស្តីពីដំណើររបស់សាវ័កប៉ុល ដែលលោកមានប្រសាសន៍ត្រង់ខ៤ខាងលើ។ អ្នកខ្លះទៀតយកសេចក្តីនោះមកបង្រៀនជាសេចក្តីអធិប្បាយ ជាឈុត ច្រើនលើក ច្រើនបែប ច្រើនបទ។ ប៉ុន្តែ សាវ័កប៉ុលខ្លួនលោកវិញលោកអះអាងថា លោកមិនដឹងទេ។ លោកគ្រាន់តែបរិយាយបន្តិចបន្តួចប៉ុណ្ណោះ។ លោកមិនបាននិយាយអ្វីអោយវែងឆ្ងាយពីដំណើរស្ថានសួគ៌ជាន់ទីបីនោះឡើយ។ ដូច្នេះ យើងមិនចាំបាច់និយាយអ្វីអោយវែងឆ្ងាយ ក្រែងលោយើងធ្លាក់ខ្លួនទៅក្រាបថ្វាយបង្គំដល់សាវ័កប៉ុលវិញ។

> **ខ្ញុំនឹងមានសេចក្តីអំនួតពីមនុស្សនោះ ខ្ញុំមិនអួតពីខ្លួនខ្ញុំទេ លើកតែពីសេចក្តីកំសោយរបស់ខ្ញុំចេញ ៦ទោះបើខ្ញុំចង់អួតខ្លួន នោះគង់តែខ្ញុំមិនមែនខ្លៅល្ងង់ទេ ដ្បិតខ្ញុំ និយាយតាមតែសេចក្តីពិត ប៉ុន្តែខ្ញុំឈប់ស្ងេះចុះ ក្រែងអ្នកណារាប់ខ្ញុំ ទុកជាលើសជាងភាពដែលឃើញ ឬឮនិយាយពីខ្ញុំ (២កូរិនថូស១២:៥-៦)។**

ក្នុងការបម្រើព្រះអម្ចាស់ យើងមិនត្រូវសរសើរខ្លួនឯង ឬអោយគេសរសើរយើងក៏មិនត្រូវដែរ។ ព្រះវិញ្ញាណរបស់ព្រះលើកសាវ័កប៉ុលទៅដល់ស្ថានសួគ៌ជាន់ទីបី។ លោកបានឮសម្លេងដែលលោកមិនអាចពណ៌នាបាន។ បុគ្គលដដែលនេះ គឺជាបុគ្គលដែលគេចាប់ដាក់កញ្ជើសម្រូតតាមកំផែងទីក្រុង ដើម្បីគេចពីសត្រូវរបស់លោក។

## បន្លានៅក្នុងចិត្តសាវ័កប៉ុល

**ហើយក្រែងខ្ញុំកើតមានចិត្តធំ ដោយព្រោះការបើកសំដែងដ៏ហួសល្បត់នោះ បានជាមានបន្លា១ចាត់មកក្នុងសាច់ឈាមខ្ញុំ គឺជាទេវតារបស់អារក្សសាតាំង ដែលមកធ្វើទុក្ខខ្ញុំ ដើម្បីកុំឱ្យខ្ញុំមានចិត្តធំឡើយ (២កូរិនថូស១២:៧)។**

សាវ័កប៉ុលអួតពីសេចក្តីទន់ខ្សោយរបស់លោក តែលោកមិនហ៊ានអួតប្រាប់យើងអំពីសភាពការណ៍ ដែលកើតមាននៅក្នុងស្ថានសួគ៌ជាន់ទីបីទេ។ តើដោយសារមូលហេតុអ្វី? ពីព្រោះមានគេប្រាប់លោកថា មិនអោយលោកនិយាយពីដំណើរនោះ។

ខ្ញុំយល់ថា សាតាំងបិទបាំងសេចក្តីល្អដែលព្រះបានធ្វើនៅលើលោកយើងនេះក្នុងរូបភាព ជាច្រើនបែបច្រើនបទ។ សាតាំងមិនចង់អោយមនុស្សលោកដឹងថា

ព្រះមានព្រះទ័យល្អទេ។ សាតាំងប្រើជម្ងឺ ប្រើសេចក្ដីឈឺចាប់ ព្រមទាំងប្រើបន្លាមកចាក់នៅក្នុងសាច់ ដើម្បីបង្អាប់ព្រះនាមព្រះជាម្ចាស់។

សាវ័កប៉ុលមានប្រសាសន៍ថា មានបន្លាចាក់នៅក្នុងសាច់លោក។ តើអ្វីទៅដែលជាបន្លាចាក់នៅក្នុងសាច់របស់សាវ័កប៉ុល? ខ្ញុំចង់ជម្រាបលោកអ្នកបងប្អូន ពីអាថ៌កំបាំងមួយ ដែលសាវ័កប៉ុលនិយាយរឿងនេះ។ ឯអាថ៌កំបាំងនោះទៀតសោត ពិបាកយល់ណាស់។ តើលោកអ្នកចង់ដឹងថា អាថ៌កំបាំងនោះជាអ្វីដែរឬទេ? ខ្ញុំក៏មិនដឹងដែរ។ ខ្ញុំមិនដឹងថា សាវ័កប៉ុលបានឃើញនិងឮអ្វីខ្លះ ពេលលោកទៅដល់ស្ថានសួគ៌ជាន់ទីបី។ ខ្ញុំក៏មិនដឹងថា តើបន្លាអ្វីដែលចាក់ក្នុងសាច់របស់សាវ័កប៉ុល? ខ្ញុំមិនអាចដឹងបាន ពីព្រោះលោកមិនបានប្រាប់យើង។

មានគ្រូអធិប្បាយព្រះបន្ទូលមួយរូបជនជាតិស្កុតឡិនហ៊ានសន្និដ្ឋានថា បន្លាដែលចាក់ក្នុងសាច់លោកប៉ុល គឺភរិយារបស់លោក។ បើតាមខ្ញុំយល់គ្រូអធិប្បាយរូននេះប្រហែលជាមានបញ្ហានៅក្នុងផ្ទះរបស់គាត់ហើយមើលទៅ។ ការសន្និដ្ឋាននេះពិតជាខុសស្រឡះ។ បើតាមការសន្និដ្ឋានរបស់ខ្ញុំ សាវ័កប៉ុលធ្លាប់មានភរិយាម្ដង ប៉ុន្តែ លោកនៅជាពោះម៉ាយបន្ទាប់ពីភរិយារបស់លោកទទួលមរណៈភាពទៅ។ លោកពណ៌នាអំពីកិរិយាស្ត្រី ដែលស្រឡាញ់ដល់ព្រះជាម្ចាស់។ បើតាមខ្ញុំយល់ លោកមានភរិយាមួយរូបដែលមានកិរិយាជិតស្មើនឹងស្ត្រីគ្រប់លក្ខណ៍។ អត់ពីភរិយាទៅ លោកមិនបានរៀបការជាមួយស្ត្រីណាទៀតទេ ពីព្រោះលោកមិនចង់អោយភរិយារបស់លោកមានការលំបាកដូចជាលោក។

ស្ដីពីបន្លានៅក្នុងចិត្តរបស់សាវ័កប៉ុល លោកមិនបានបង្ហើបរឿងនោះអោយយើងដឹងទាល់តែសោះ។ គេតែងតែនិយាយថា សត្វឆ្កែមានមិត្តភក្ដិច្រើន ពីព្រោះវាបក់កន្ទុយដាល់គេដាក់ឯងជានិច្ច។ សាវ័កប៉ុលមិនបក់អណ្ដាតរបស់លោក ពីដំណើរស្ថានសួគ៌ជាន់ទីបីទេ។ បើសិនជាមានអ្នកណាម្នាក់បានឡើងទៅដល់ស្ថានសួគ៌ជាន់ទីបីមែន ម្ល៉េះសមមកវិញគេបក់អណ្ដាតញាប់ជាងឆ្កែបក់កន្ទុយទៀត។ ឥឡូវនេះយើងសួរថា ហេតុអ្វីបានជាព្រះជាម្ចាស់កណ្ដាល អោយមានបន្លាមួយសម្រាប់ចាក់ក្នុងសាច់សាវ័កប៉ុល? មូលហេតុនោះ គឺព្រះអង្គចង់អោយសាវ័កប៉ុលបម្រើទ្រង់ដោយបន្ទាបខ្លួន។ ម្យ៉ាងទៀត គឺមិនចង់អោយលោកលើកតម្កើងខ្លួនឯងលើសពីខ្នាតដែលព្រះជាម្ចាស់អោយលោកឃើញនៅក្នុងនិម្មិតរបស់លោក។

**៨ ខ្ញុំបានសូមអង្វរដល់ព្រះអម្ចាស់៣ដង ឱ្យសេចក្ដីនោះថយចេញពី**
**ខ្ញុំទៅ ៩ តែទ្រង់មានបន្ទូលមកខ្ញុំថា គុណរបស់អញល្មមដល់ឯង**
**ហើយ ដ្បិតកំឡាំងអញបានពេញខ្នាត ដោយសេចក្ដីកំសោយ**
**ដូច្នេះ ខ្ញុំនឹងស៊ូអួតពីសេចក្ដីកំសោយរបស់ខ្ញុំដោយអំណរជាខ្លាំង**
**ដើម្បីឱ្យព្រះចេស្ដានៃព្រះគ្រីស្ទបានសណ្ឋិតនៅនឹងខ្ញុំ (២កូរិនថូស**
**១២:៨-៩)។**

បើតាមការសន្និដ្ឋាន បន្លាដែលចាក់សាច់លោកនោះ គឺលោកមានរោគអៀស៊ីភ្នែក។ ពេលយើងសិក្សាសំបុត្ររបស់លោក ដែលលោកបានសរសេរទៅកាន់ក្រុមជំនុំនៅទីក្រុងកាឡាទី យើងឃើញថា លោកសរសេរទៅកាន់ពួកជំនុំដោយអក្សរធំៗ។ លោកសរសេរអក្សរធំ ម្យ៉ាងអាចមកពីលោកពិបាកអាន។ យើងនឹងពិភាក្សារឿងនេះនៅពេលយើងសិក្សាមេរៀននោះ។ ទោះបីបន្លាដែលចាក់សាច់លោកប៉ុលជាអ្វីក៏ដោយ លោកអធិស្ឋានដល់ព្រះជាម្ចាស់ចំនួនបីដង អោយព្រះអង្គដលបន្លានោះចេញទេ។ ប៉ុន្តែទោះជាយ៉ាងនោះក៏ដោយ ព្រះជាម្ចាស់បដិសេធមិនព្រមដកបន្លានោះចេញទេ។ ព្រះអម្ចាស់ស្ដាប់ឮសេចក្ដីអធិស្ឋានរបស់សាវ័កប៉ុល លើកទីមួយ លើកទីពីរ និងលើកទីបីទីបួន...ផង។ ការដែរព្រះជាម្ចាស់មិនដកបន្លា មិនមែនមានន័យថា ព្រះអង្គស្ដាប់មិនឮសេចក្ដីអធិស្ឋានរបស់លោកទេ។ ព្រះជាម្ចាស់ឆ្លើយមកសាវ័កប៉ុលវិញថា "ទេ"។

ជួនកាលទាំងរូបខ្ញុំ ទាំងរូបលោកអ្នកតែងតែទូលសូមដល់ព្រះជាម្ចាស់នូវអ្វីដែលព្រះអង្គបានផ្ដល់ចម្លើយរួចទៅហើយ។ ព្រះអង្គមិនចង់ប្រទានសំណូមដែលយើងសូម ពីព្រោះទ្រង់សព្វព្រះហឫទ័យថា ជីវិតរស់នៅរបស់យើងល្អជាង បើគ្មានរបស់ដែលយើងទូលសូមនោះ។ ចម្លើយរបស់ទ្រង់ភាគច្រើនគឺទេ។ ចំពោះរូបខ្ញុំ កាលណាព្រះអង្គឆ្លើយថាទេ ការនោះល្អសម្រាប់រូបខ្ញុំ ជាងព្រះអង្គអោយតាមខ្ញុំសូម។

សាវ័កប៉ុលមានប្រសាសន៍នៅក្នុង៦៩នេះ ជាព្រះបន្ទូលដែលជម្រះមន្ទិលក្នុងជីវិតរបស់យើង។ សាវ័កប៉ុលមានប្រសាសន៍ថា "តែទ្រង់មានបន្ទូលមកខ្ញុំថា គុណរបស់អញ ល្មមដល់ឯងហើយ..."។ ព្រះជាម្ចាស់មិនបានដកបន្លាដែលចាក់សាច់លោកប៉ុលទេ

តែទ្រង់ប្រទានព្រះគុណជាបរិបូរ ដើម្បីអោយសាវ័កប៉ុលអាចទ្រាំទ្រនឹងបន្ទាដែលកំពុងតែចាក់សាច់ក្នុងលោក។ សេចក្តីពិតនេះមានខ្លឹមសារយ៉ាងជ្រាលជ្រៅនៅក្នុងជីវិតរបស់យើងជាអ្នកបម្រើព្រះអង្គ និងជាកូនរបស់ព្រះវរបិតា។ សាវ័កប៉ុលបន្ថែមទៀតថា "...ដ្បិតកំឡាំងអញបានពេញខ្នាត ដោយសេចក្តីកំសោយ..."។ ឃ្លានេះមានន័យថា ពេលដែលសាវ័កប៉ុលបម្រើព្រះអង្គ លោកមានរូបកាយទន់ខ្សោយ តែព្រះវិញ្ញាណរបស់ព្រះបានផ្តល់ចេស្តាដល់លោក ដើម្បីអោយលោកបម្រើព្រះជាម្ចាស់បានចប់ចុងចប់ដើម។ ដូច្នេះហើយបានជាលោកបញ្ជាក់បន្ថែមទៀតថា "...ខ្ញុំនឹងស៊ូអួតពីសេចក្តីកំសោយរបស់ខ្ញុំដោយអំណរខ្លាំង ដើម្បីឱ្យព្រះចេស្តានៃព្រះគ្រីស្ទបានសណ្ឋិតនៅនឹងខ្ញុំ" សាវ័កប៉ុលឆ្លើយទទួលយ៉ាងរីករាយចំពោះចម្លើយដែលព្រះជាម្ចាស់ផ្តល់មកលោក។ ចម្លើយនោះ គឺ "ទេ!" សាវ័កប៉ុលលើកសរសើរតម្កើងដល់ព្រះជាម្ចាស់ ទោះបីលោកមានភាពពិការក្នុងរូបសាច់របស់លោកក៏ដោយ។ លោកមិនសរសើរខ្លួនលោកដោយសារលោកបានឃើញហេតុការណ៍ ដែលកើតឡើងនៅស្ថានសួគ៌ជាន់ទីបីជាដាច់ខាត។ ដូច្នេះ មេរៀននេះគឺ សម្រាប់រូបលោកអ្នកហើយនិងរូបខ្ញុំផ្ទាល់។ ថ្ងៃក្រោយ បើមានឮអ្នកណាហ៊ានមកអួតអាងថា ខ្លួនបានឃើញនិម្មិតមកពីស្ថានសួគ៌ យើងគួរសួរខ្លួនឯងឬសួរដល់អ្នកនោះថា នៅក្នុងព្រះគម្ពីរមានមនុស្សបីនាក់ដែលធ្វើដំណើរទៅដល់ស្ថានសួគ៌ជាន់ទីបី។ អ្នកទាំងនោះ គឺព្រះអម្ចាស់យេស៊ូវគ្រីស្ទ សាវ័កយ៉ូហាន និងសាវ័កប៉ុល។ លោកជាមនុស្សរបស់ព្រះ តែមិនហ៊ាននិយាយច្រើន ពីដំណើរហេតុការណ៍ដែលកើតឡើងនៅស្ថានសួគ៌ជាន់ទីបីឡើង។ តើមានមនុស្សណាទៅដែលហ៊ានអួតអាងថា ខ្លួន

បានឃើញនិម្មិតដែលព្រះជាម្ចាស់បើកអោយឃើញនៅឯស្ថានសួគ៌ជាន់ទីបី? បុគ្គលណាដែលហ៊ាននិយាយថា ខ្លួនបានឃើញហេតុការណ៍ ដែលព្រះជាម្ចាស់បើកសម្តែងអោយឃើញស្ថានសួគ៌នៅជាន់ទីបី គួរយកម្ជុលដេរមាត់បាវ ដេរមាត់ខ្លួនឯងអោយជិតទៅកុំអោយនិយាយនាំខ្មាសគេ។ បើតាមខ្ញុំយល់ អ្នកដែលអះអាងថាបានឃើញស្ថានសួគ៌ជាន់ទីបី ប្រហែលជាបរិភោគអាហារពុលពីក្បាលល្ងាចទេដឹង។

**ហេតុនោះ បានជាខ្ញុំអរសប្បាយក្នុងកាលដែលមានសេចក្តីកំសោយ ក្នុងកាលដែលគេត្មះតិះដៀល ក្នុងសេចក្តីលំបាក កាលគេធ្វើទុក្ខបៀតបៀន ហើយក្នុងសេចក្តីដែលខ្ញុំត្រូវចង្អៀតចង្អល់ដោយយល់ដល់ព្រះគ្រីស្ទ ដ្បិតកាលណាខ្ញុំខ្សោយ នោះខ្ញុំមានកំឡាំងយ៉ាងចំណានវិញ (២កូរិនថូស១២:១០)។**

បើយើងប្រៀបធៀបសាវ័កប៉ុល ទៅនឹងលោកសាំសុននៅក្នុងព្រះគម្ពីរសញ្ញាចាស់ បុគ្គលិកលក្ខណៈរបស់បុគ្គលទាំងពីររូបនេះ ខុសគ្នាដូចមេឃហើយនិងដី។ ព្រះវិញ្ញាណរបស់ព្រះបណ្តាលអោយលោកសាំសុនមានកម្លាំងខ្លាំង។ មនុស្សលោកសម័យនោះ កោតសរសើរពីកម្លាំងបាយរបស់លោកសាំសុនណាស់។ ប៉ុន្តែ ថ្ងៃមួយសាំសុនមានភាពទន់ខ្សោយយ៉ាងខ្លាំង។ មនុស្សដែលខ្លាំងព្រះអង្គធ្វើអោយខ្សោយ រីឯមនុស្សខ្សោយ ព្រះអង្គធ្វើអោយខ្លាំងវិញ។ ព្រះជាម្ចាស់ប្រើមនុស្សណាដែលទទួល

ស្គាល់ភាពទន់ខ្សោយរបស់ខ្លួន។

> **ខ្ញុំបានត្រឡប់ជាល្ងង់ខ្លៅ ដោយសេចក្តីអំនួត គឺអ្នករាល់គ្នាបានបង្ខំខ្ញុំ ដ្បិតគួរឲ្យអ្នករាល់គ្នាបានផ្ទុកផ្តាក់ខ្ញុំវិញ នោះបើខ្ញុំមិនមែនជាអ្វីក៏ដោយ គង់តែខ្ញុំមិនចាញ់ពួកសាវ័កធំណាមួយនោះទេ (២កូរិនថូស១២:១១)។**

សាវ័កប៉ុលបរិយាយលំអិតពីដំណើរនេះបន្តិច។ លោកបានសំទោសគេម្តងទៀត ដូចជាលោកបានធ្វើជាច្រើនដងកន្លងមក។ លោកមានប្រសាសន៍ថា លោកជាសាវ័កដ៏តូចទាបបំផុត ប៉ុន្តែ បើប្រៀបធៀបជាមួយនឹងសាវ័កដទៃៗទៀត លោកមិនមែនជាមនុស្សដែលគេរាប់ថា គ្មានប្រយោជន៍នោះឡើយ។ ក្នុងចំណោមសិស្សរបស់សាវ័កប៉ុលគួរតែមានអ្នកឯទៀត ហ៊ាននិយាយជំនួសសាវ័កប៉ុលថា លោកជាសាវ័ករបស់ព្រះអម្ចាស់។ ប៉ុន្តែ គ្មានអ្នកណាមួយផ្តល់កិត្តិយល់ដល់លោកសោះ បានជាលោកចាំបាច់ត្រូវនិយាយរឿងនេះថា លោកជាសាវ័ករបស់ព្រះអម្ចាស់។

> **ពិតមែន មានភស្តុតាងបានកើតឡើងក្នុងពួកអ្នករាល់គ្នា ដើម្បីនឹងបញ្ជាក់ការងារជាសាវ័ករបស់ខ្ញុំ ដោយការអត់ធន់ ដោយទី**

### សំគាល់ ការអស្ចារ្យ នឹងការឫទ្ធិបារមីគ្រប់យ៉ាង (២កូរិនថូស ១២:១២)។

ដើម្បីផ្តល់ជាផ្លាកសញ្ញាថា សាវ័កប៉ុលពិតជាសាវ័ករបស់ព្រះអម្ចាស់មែន ព្រះជាម្ចាស់ប្រទានអោយលោកមានអំណោយទានជាច្រើន។ អំណោយទានមួយ គឺការប្រោសមនុស្សអោយជា។ អំណោយទានមួយទៀតគឺ និយាយភាសាដទៃ។ ការនិយាយភាសាដទៃគឺ និយាយភាសារបស់មនុស្សជាសាសន៍ដទៃ។ តើលោករៀនភាសាទាំងនោះពីអ្នកណា ដ្បិតមនុស្សដែលលោកចេញទៅផ្សាយដំណឹងល្អនោះ មានអ្នកនិយាយភាសាចំនួនប្រហែលជាហាសិបឯណោះ។ សាវ័កប៉ុលអាចនិយាយភាសាទាំងអស់នោះបាន។ ព្រះជាម្ចាស់បណ្តាលអោយលោកអាចនិយាយភាសាទាំងនោះ។ សព្វថ្ងៃបេសកជនគ្មានអំណោយទាននោះទេ។ គេត្រូវរៀនភាសាគេអស់រយៈពេលជាច្រើនឆ្នាំ ទើបអាចចេះផ្សព្វផ្សាយដំណឹងល្អដល់អ្នកភូមិអ្នកស្រុកដែលគេទៅស្នាក់នៅជាមួយ។

នៅក្នុងបទគម្ពីរដែលយើងសិក្សាថ្ងៃនេះ មានសេចក្តីពិតជាច្រើនយ៉ាង។ សាវ័កប៉ុលបានធ្វើដំណើរទៅដល់ស្ថានសួគ៌ជាន់ទីបី ជាដំណាក់ព្រះជាម្ចាស់គង់នៅ។ លោកមិននិយាយពីរឿងនោះទេ។ លោកចាំបាច់ត្រូវនិយាយប្រាប់គេពីអង្គព្រះយេស៊ូវគ្រីស្ទជាអង្គសង្គ្រោះ។ ស្ថានសួគ៌ជាកន្លែងប្រសើរឧត្តម តែព្រះបន្ទូលរបស់ព្រះសម្តែងតិចណាស់ពីដំណើរនោះ។ ព្រះបន្ទូលរបស់ព្រះសម្តែងយ៉ាងច្រើន ពីអង្គព្រះយេស៊ូវជាអង្គសង្គ្រោះ ដែលអាចនាំមនុស្សលោកទៅដល់ស្ថានសួគ៌។

ខ្ញុំក៏ដូច្នោះដែរ ខ្ញុំមិនអាចនិយាយបីស្ថានសួគ៌បានច្រើនទេ។ ប៉ុន្តែ ខ្ញុំអាចនិយាយប្រាប់លោកអ្នកពីព្រះមួយអង្គ ដែលយាងចុះពីស្ថានសួគ៌។ ព្រះអង្គនោះមាននាមថា ព្រះយេស៊ូវគ្រីស្ទ។ យើងត្រូវផ្តោតភ្នែកយើងអោយចំអង្គព្រះយេស៊ូវ។ សាវ័កប៉ុលសរសេរទៅកាន់ពួកជំនុំរបស់ព្រះជាម្ចាស់ ស្តីពីការសម្លឹងអោយចំអង្គព្រះយេស៊ូវគ្រីស្ទជាអង្គសង្គ្រោះ។ កំពុងតែយើងធ្វើដំណើរកាត់លោកសន្និវាសនេះ យើងត្រូវផ្តោតភ្នែកយើងអោយចំអង្គព្រះយេស៊ូវគ្រីស្ទ។ បើយើងធ្វើយ៉ាងដូច្នោះ ពន្លឺថ្ងៃអាក្រក់មិនអាចវាយយើងបានទេ។ ព្យុះដែលបក់បោកមកលើយើង ក៏មិនអាចធ្វើអោយនាវាជីវិតរបស់យើងវេខុសទិសដៅបានដែរ បើយើងផ្តោតភ្នែកយើងចំអង្គព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់។

យើងស្លេះការសិក្សាគម្ពីរ២កូរិនថូសត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"។